# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ )

ភាគីដាក់ឯកសារ: ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:13
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ : សាធារណៈ/Public

ប្រភេទចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតប របស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវី</u>**

ប៊ិត ស៊ាងលីម

Wayne JORDASH, QC

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម BAIK Kang Jin

ចៅក្រម ន័យ ធុល

ចៅក្រម Oivier BEAUVALLET

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**ទាំងអស់ក្នុងសំណុំរឿង ០០៤/១**

## I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី (“ក្រុមការពារក្តី”) តទៅនេះ សូមដាក់ជូនសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ (“សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ”) អនុលោមតាមមាត្រា ៩.១ នៃសេចក្តីណែនាំការអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង និងអនុលោមតាមមាត្រា ៣.១២ និង មាត្រា ៣.១៤ នៃសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ។ ក្រុមការពារក្តីសូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តាធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាប្រភេទឯកសារសាធារណៈនៃ*ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង*[1] ដោយភ្ជាប់ជាមួយនឹងសំណូមពរសុំធ្វើការកោសលុបនៅក្នុងឧបសម្ព័ន្ធ A[2] ។ សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នឹងធានាថាទទ្បីករណ៍នានារបស់ក្រុមការពារក្តីទាក់ទងនឹងសំណុំរឿង ០០៤/១ អាចឱ្យសាធារណជនរកមើលបាន ហើយដែលព័ត៌មានទូទៅទាំងនោះ នឹងត្រូវបានផ្តល់ជូនប្រកបដោយតុល្យភាព ដើម្បីធានាពីតម្លាភាពនៃការគ្រប់គ្រងលើវិស័យយុត្តិធម៌ និងសុចរិតភាពកេរដំណែលរបស់ អ.វ.ត.ក ។ សំណើបន្ថែមរបស់ក្រុមការពារក្តី គឺសុំដាក់សំណើធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ឱ្យទៅជាប្រភេទឯកសារសាធារណៈ បន្ទាប់ពីមានការកោសលុបសមរម្យត្រូវបានអនុវត្ត ។

២. ការដាក់នូវសំណើសុំនេះគឺមានភាពសមរម្យ និងទាន់ពេលវេលានៅក្នុងដំណាក់កាលនៃនីតិវិធីបច្ចុប្បន្ន ។ ប្រសិនបើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកា

---

[1] ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ធ្វើនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/6** (“ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6**”) ។

[2] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ, ឧបសម្ព័ន្ធ A: (“សំណៅកោសលុបជាសាធារណៈនៃចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង”) (“ឧបសម្ព័ន្ធ A”) ។

ដំណោះស្រាយ (សំអាងហេតុ)[3] ត្រូវបានបដិសេធ ហើយនីតិវិធីទាំងអស់ក្នុងសំណុំរឿង ០០៤/១ ត្រូវបានបញ្ចប់ជាស្ថាពរ ដល់ពេលនោះអ្នកស្រី អ៊ឹម ចែម នឹងមិនអាចប្រើប្រាស់សិទ្ធិពិភាក្សាដេញដោលរបស់ខ្លួន លើបញ្ហានេះទៀតបានទេ ។

## II. សាវតារ

៣. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរលើសំណុំរឿង ០០៤/១ ចំនួនពីរដាច់ដោយឡែកពីគ្នា[4] ។ សហព្រះរាជអាជ្ញាជាតិបានស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[5] ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យនាំខ្លួន ឃុំខ្លួន និងបញ្ជូនអ្នកស្រី អ៊ឹម ចែម ទៅជំនុំជម្រះ[6] ។

៤. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ក្រុមការពារក្តីបានដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបានស្នើសុំឱ្យធ្វើការច្រានចោលនូវបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី ផ្អែកលើមូលដ្ឋាននៃការខ្វះយុត្តាធិការបុគ្គល[7] ។

៥. នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ ការិយាល័យសហព្រះរាជអាជ្ញាបានចេញជាសាធារណៈនូវសេចក្តីសង្ខេបនៃដីកាសន្និដ្ឋានស្ថាពរទាំងពីរក្នុងសំណុំរឿង ០០៤/១ យោងតាមវិធាន ៥៤ ដោយអះអាងថា ការមាន "តម្លាភាពនឹងធ្វើជាវិភាគទានដល់ទំនុកចិត្តរបស់សាធារណជននៅក្នុងស្ថាប័ន

3 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/1** ។

4 ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/1**; ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន៦៦ នៃផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **D304/2** ("ដីកាសន្និដ្ឋានស្ថាពរ") ។

5 ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦, ឯកសារ **D304/1** ត្រង់កថាខណ្ឌ ៣៨ ។

6 ដីកាសន្និដ្ឋានស្ថាពរ ត្រង់កថាខណ្ឌ ៥៣៩-៤១ ។

7 ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** ។

តុលាការ"[8] ។ នៅក្នុងសេចក្តីសង្ខេប សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ពីចេតនា "សុំឱ្យសហចៅក្រមស៊ើបអង្កេត ដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន និងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននេះ ឱ្យទៅជាសាធារណៈ បន្ទាប់ពីការកោសលុបត្រឹមត្រូវមួយត្រូវបានធ្វើឡើងដើម្បីការពារសន្តិសុខ និងឯកជនភាពរបស់សាក្សី និងជនរងគ្រោះ"[9] ។

៦. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានដាក់ចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ជាសំណៅកោសលុបសាធារណៈ និងបានច្រានចោលនូវរាល់បទចោទប្រកាន់ទាំងអស់លើអ្នកស្រី អ៊ឹម ចែម[10] ។

## III. ច្បាប់ជាធរមាន

### ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវសារណានានា

៧. អនុលោមតាមមាត្រា ៩.១ នៃសេចក្តីណែនាំការអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង និងមាត្រា ៣.១២ នៃសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ចែងថា រាល់ឯកសារ និងព័ត៌មានទាំងឡាយអាចត្រូវបានចាត់ថ្នាក់ឡើងវិញទៅបាន លុះត្រាតែមានសេចក្តីបង្គាប់ពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមករណីសមស្រប ។ យោងតាមមាត្រា ៣.១៤ នៃសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះពាក់ព័ន្ធអាចផ្តល់ឱកាសឱ្យភាគីនានាធ្វើការពិភាក្សាដេញដោល មុនពេលធ្វើការសម្រេចលើការធ្វើចំណាត់

---

[8] សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០៤/០១ [យោងតាម] វិធាន ៥៤ សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាស្តីពីដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹង អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៦ ។ អាចចូលមើលបាន: https://www.eccc.gov.kh/en/articles/statement-office-co-prosecutors-case-00401 ["សេចក្តីថ្លែងការណ៍ដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០៤/១ ឬ សេចក្តីសង្ខេបសាធារណៈ"] ត្រង់ទំព័រ ១ ។

[9] សេចក្តីថ្លែងការណ៍ដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០៤/១, ត្រង់ទំព័រ ៥ ។

[10] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣១២-១៣ និងកថាខណ្ឌ ៣២៥ ។

ប្រភេទឯកសារឡើងវិញ ។

**ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី**

៨. យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[11] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[12] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[13] វិធាន ២១ នៃវិធានផ្ទៃក្នុង[14] និងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[15] អ្នកស្រី អ៊ឹម ចែម មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវដំណើរការនីតិវិធីតុលាការមួយដែលប្រកបដោយតម្លាភាព យុត្តិធម៌ និងប្រព្រឹត្តទៅជាសាធារណៈ ។ វិធាន ២១(១) កំណត់អំពីគោលការណ៍គ្រឹះមួយចំនួននៃនីតិវិធីនៅ អ.វ.ត.ក និងការធានានូវសច្ចភាពផ្នែកច្បាប់ ព្រមទាំងតម្លាភាពក្នុងការអនុវត្តនីតិវិធីទាំងនោះ ។

៩. អនុលោមតាមមាត្រា ១.២ នៃសេចក្តីណែនាំការអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ការធ្វើចំណាត់ប្រភេទឯកសារ និងព័ត៌មាន ត្រូវតែមានតុល្យភាពរវាងការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងផ្នែកផ្សេងៗទៀតនៃនីតិវិធីតុលាការនានាដែលមិនត្រូវដាក់បង្ហាញដល់សាធារណជន នេះក៏ដោយសារតែភាពចាំបាច់នៅក្នុងការធានាឱ្យបាននូវតម្លាភាពនៃនីតិវិធីសាធារណៈ និងដើម្បីបំពេញនូវគោលបំណងនៃការអប់រំ ព្រមទាំង

---

[11] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (អនុម័តនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣, វិសោធនកម្មនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩) ("រដ្ឋធម្មនុញ្ញកម្ពុជា") ។

[12] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") ។

[13] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") ។

[14] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ដែលបានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥) ("វិធានផ្ទៃក្នុង") ។

[15] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦) លេខ 999 UNTS 171 ("ICCPR") ។

កេរដំណែល ។

**ទាក់ទងនឹងសំណើសុំធ្វើការកោសលុបសារណានានា**

១០. មាត្រា ៩ នៃសេចក្ដីណែនាំការអនុវត្តស្ដីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង បានចែងនូវវិធានមួយចំនួនខាងក្រោម ពាក់ព័ន្ធនឹងការកោសលុបសារណាផ្សេងៗ ដែលត្រូវបានធ្វើចំណាត់ប្រភេទឯកសារឡើងវិញរួចហើយ ដូច្នេះថា:

៩.២ អត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់បំផុត អាចត្រូវគេរៀបចំឡើងដើម្បីដាក់ក្នុងផ្នែកសាធារណៈនៃសំណុំរឿង តាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមករណីសមស្រប ។ អត្ថបទឯកសារសាធារណៈថ្មី អាចនឹងត្រូវរៀបចំតាមរយៈ ៖

ក. បង្កើតច្បាប់ចម្លងពីឯកសារច្បាប់ដើម ។

ខ. កាត់ចេញពីផ្នែកនៃច្បាប់ចម្លងពីព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតទាំងអស់តាមដែលអាចធ្វើបាន ។ និង

គ. បញ្ជូនអត្ថបទដែលបន្ទាប់ពីកាត់ចេញមកនោះទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដើម្បីពិនិត្យឡើងវិញ និងសម្រេច មុននឹងដាក់ឯកសារទាំងនោះចូលទៅក្នុងផ្នែកសាធារណៈនៃសំណុំរឿង ។

អត្ថបទឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុត អាចត្រូវគេរៀបចំធ្វើឡើងតាមរបៀបប្រហាក់ប្រហែលគ្នានេះដែរ ។

៩.៣ បើសិនអត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់បំផុតត្រូវបានរៀបចំធ្វើតាមសំណើភាគីមួយ ការកាត់ចេញផ្នែកណាខ្លះណាមួយ ត្រូវធ្វើឡើងដោយភាគីស្នើសុំ និងដាក់ស្នើសុំការអនុញ្ញាត ដោយអនុលោមតាមមាត្រា ៩.២(គ) ។

១១. មាត្រា ៣(១)(ឃ) នៃសេចក្ដីណែនាំការអនុវត្តស្ដីពីវិធានការការពារ តម្រូវឱ្យធ្វើការដកចេញពីកំណត់ត្រា នូវរាល់ព័ត៌មានទាំងឡាយណា ដែលអាចកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវទទួលបានការការពារ ឬព័ត៌មានផ្សេងទៀតដែលអាចបង្ហាញអំពីអត្តសញ្ញាណ ឬទីកន្លែងរបស់ជនណាម្នាក់នោះ ។

## IV. ឧទ្ធីករណ៍

១២. ចំពោះហេតុផលទាំអម្បាលម៉ានដូចមានរៀបរាប់នៅខាងក្រោមនេះ ក្រុមការពារក្តីសូមស្នើថា ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ គឺមិនកាត់បន្ថយផលប្រយោជន៍ដែលការពារដោយភាពសម្ងាត់នៃកិច្ចស៊ើបអង្កេតឡើយ (ផ្នែក **ក**) ហើយសំណើនេះ នឹងកាន់តែធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍យុត្តិធម៌ (ផ្នែក **ខ**) ។

### ក. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ មិនធ្វើឱ្យប៉ះពាល់ដល់ភាពសម្ងាត់នៃកិច្ចស៊ើបសួរ

១៣. នៅពេលវាយតម្លៃឱ្យមានតុល្យភាពល្អបំផុត រវាងភាពសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងផលប្រយោជន៍តម្លាភាពនៅក្នុងដំណើរការនីតិវិធី លក្ខខណ្ឌតម្រូវគឺថា ប្រសិនបើមានមូលហេតុដែលត្រូវធ្វើចំណាត់ប្រភេទឯកសារណាមួយជាឯកសារសម្ងាត់ទៀតហើយនោះ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសមស្របណាមួយ អាចពិចារណាធ្វើចំណាត់ប្រភេទឯកសារនោះឡើងវិញ ដោយដាក់ជាឯកសារសាធារណៈ[16] ។ ក៏ប៉ុន្តែភាពសម្ងាត់នៃកិច្ចស៊ើបសួរ អាចនឹងនៅតែតម្រូវឱ្យព័ត៌មានរសើបទាំងឡាយ គប្បីត្រូវទទួលបានការការពារ ។

១៤. ដូចដែលក្រុមការពារក្តីបានលើកឡើងរួចមកហើយ នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ភាពសម្ងាត់នៃកិច្ចស៊ើបសួរ មិនបានបញ្ឈប់ការអនុវត្តត្រឹមការ

[16] *សូមមើល, សំណុំរឿងលោក មាស មុត, រឿងក្តីលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ចៅ.ស,* ដីកាសម្រេចលើសំណើរបស់ មាស មុត សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាឯកសារសាធារណៈ ដោយមានឧបសម្ព័ន្ធ “ក” និង “ខ” ជាឯកសារសាធារណៈ និងឧបសម្ព័ន្ធ “គ” ជាឯកសារសម្ងាត់ ធ្វើនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D129/1** ត្រង់កថាខណ្ឌ ១១ ។

បញ្ចប់នូវកិច្ចស៊ើបអង្កេតនោះទេ[17] ។ លើសពីនេះទៀត ថាតើកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៤/១ ត្រូវបានបញ្ចប់ទៅដូចគ្នានឹងករណីក្នុងសំណុំរឿង ០០១ ដែរឬយ៉ាងណានោះ ការធ្វើចំណាត់ប្រភេទឯកសារទាំងឡាយ នៅតែត្រូវបានកំណត់តាមរយៈការវាយតម្លៃលើការពិចារណាលើហេតុផលផ្សេងៗគ្នានានា ដែលពាក់ព័ន្ធនឹងការការពារនូវព័ត៌មានរសើបមួយចំនួន រាប់បញ្ចូលទាំងការកំពុងបន្តទៅមុខនៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ហានិភ័យនៃផលប៉ះពាល់ដល់ជនត្រូវចោទ ឬផលប៉ះពាល់ដល់កិច្ចស៊ើបសួរដែលកំពុងមានស្រាប់ ព្រមទាំងមានបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងភាពសម្ងាត់[18] ។

១៥. ចំពោះហេតុផលដូចបានរៀបរាប់ខាងក្រោមនេះ ក្រុមការពារក្តីសូមស្នើថា ការកោសលុបមួយចំនួននៅក្នុងឧបសម្ព័ន្ធ A ដែលភ្ជាប់ជាមួយនឹងញត្តិនេះ គឺប្រកបដោយតុល្យភាពសមរម្យ និងមានភាពចាំបាច់រវាងការពិចារណាលើហេតុផលទាំងឡាយផ្សេងៗគ្នាទាំងនេះ ដោយផ្ទៀងផ្ទាត់ជាមួយនឹងអត្ថប្រយោជន៍នានាក្នុងសំណុំរឿង ដែលត្រូវបានការពារដោយភាពសម្ងាត់នៃកិច្ចស៊ើបសួរ និងអត្ថប្រយោជន៍ពីនីតិវិធី និងផ្នែកនៃសេចក្តីសម្រេចនៅពេលត្រូវបានដាក់ជាសាធារណៈ ។

១៦. ក្នុងករណីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់កាលនាពេលកន្លងទៅ ពីការគាំទ្ររបស់គាត់

---

[17] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេច លើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ), ធ្វើនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារ **D308/2/1/3** ត្រង់កថាខណ្ឌ ៣៨-៣៩ ។

[18] *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៦ ["ដោយហេតុថា កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០១ បានបញ្ចប់រួចហើយ ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធកិច្ចស៊ើបសួរ លែងមានហានិភ័យជាទូទៅនៃការប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ជាគោលការណ៍ ឯកសារប្រភេទនេះទាំងអស់ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជាឯកសារសាធារណៈ ដូច្នេះត្រូវអនុញ្ញាតឱ្យសាធារណជនទូទៅ មានលទ្ធភាពពេញលេញនៅក្នុងការពិនិត្យមើលឯកសារ និងពង្រីកឱ្យមានតម្លាភាពដល់កម្រិតអតិបរិមា ។ នៅក្នុងពេលជាមួយគ្នានេះ ដោយពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅកំពុងបន្តដំណើរការនៅឡើយ ហើយបន្ទាប់ពីបញ្ចប់កិច្ចដំណើរការនីតិវិធីនេះ ការសម្ងាត់ចំពោះសំអាងមួយចំនួន អាចនៅតែរក្សាទុកការពារមួយចំនួនចាំបាច់តម្រូវឱ្យមាន ដូចដែលមានកំណត់នៅក្នុងគោលការណ៍ណែនាំខាងក្រោម"] ។

ចំពោះការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដែលបានលើកឡើងដោយក្រុមការពារក្តីនៅក្នុងចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[19] ។ លើសពីនេះទៅទៀត អនុលោមតាមការបិទជាផ្លូវការនៃផ្នែកស៊ើបសួរ គ្មានហេតុផលអ្វីសេសសល់សម្រាប់រក្សានូវភាពសម្ងាត់ចំពោះចំណាត់ប្រភេទឯកសារចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះឡើយ ។ ការពិតដែលការស៊ើបអង្កេតតាមផ្លូវតុលាការប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម គឺត្រូវបានបញ្ចប់[20] ហើយរាល់ទំនាក់ទំនងណាមួយលើអង្គហេតុនានាដែលត្រូវបានស៊ើបអង្កេតរួចក្នុងសំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ព្រមទាំងសម្ភារៈតឹកតាងសម្ងាត់ទាំងឡាយណាដែលទាក់ទងនឹងសំណុំរឿង ០០៤/១ គឺសុទ្ធតែអាចនឹងត្រូវបានធ្វើការកោសលុបដោយងាយ ដូចបានស្នើឡើងស្រាប់នៅក្នុងឧបសម្ព័ន្ធ A ។ សរុបសេចក្តីមកវាហាក់ដូចជាបានព្រមព្រៀងស្រាប់ពីសំណាក់ភាគីនានាដូច្នេះដែរ ការផ្តល់តាមសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នឹងមិនប៉ះពាល់ដល់អត្ថប្រយោជន៍ណាមួយដែលកន្លងទៅត្រូវបានការពារដោយភាពសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការនោះទេ ។

១៧. ដោយពិចារណាទៅលើហេតុផលខាងលើ ក្រុមការពារក្តីបានស្នើសុំធ្វើការកោសលុបដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ A ដោយប្រើសញ្ញា “បន្ទាត់ឆូតកាត់” លើចំណុចត្រូវកោសលុប ។ ជាពិសេស៖

- ក្រុមការពារក្តីសូមស្នើឱ្យកោសលុបព័ត៌មានដែលអាចកំណត់បាននូវអត្តសញ្ញាណសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ ដោយអនុលោមតាមសេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៅក្នុងសំណុំ

[19] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងលិខិតរបស់ អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ស្តីពីការដាក់ច្បាប់កោសលុបជាសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ធ្វើនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/3/1**, ត្រង់កថាខណ្ឌ ១២ [“សពរអ នឹងគាំទ្រយ៉ាងពេញលេញចំពោះសំណោមេធាវីការពារក្តីសុំឱ្យដាក់សំណៅជាសាធារណៈដែលមានការកោសលុបត្រឹមត្រូវ នៃចម្លើយតបរបស់ពួកគាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ ធ្វើដូច្នេះ ដើម្បីឱ្យពួកគេជំទាស់ជាសាធារណៈទៅនឹងខ្លឹមសាររបស់ដីកាសន្និដ្ឋាននោះ ខណៈក្នុងពេលជាមួយគ្នានោះ ការការពារផលប្រយោជន៍របស់សាក្សី និងជនរងគ្រោះ និងការពារផលប្រយោជន៍សាធារណជនក្នុងកិច្ចការរដ្ឋបាលតុលាការប្រកបដោយតម្លាភាព”] ។

[20] សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D285** ។

រឿង០០១[21] ។ ឧទាហរណ៍ គឺរាប់ទាំងឈ្មោះសាក្សី ហៃម មាន និងតួនាទីរបស់គាត់ជានីរសាររបស់*តា ចាយ* ជាកម្មាភិបាលតំបន់ ៣ គឺត្រូវបានកោសលុបក្នុងឧបសម្ព័ន្ធ A[22] ។ ទោះជាយ៉ាងណាក្តី ឯកសារយោងទៅសាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មជាសាធារណៈនៅក្នុងសំណុំរឿង ០០១ និង/ឬនៅក្នុងសំណុំរឿង ០០២ ត្រូវបានរក្សាទុកដូចដើម ។ ជាក់ស្តែង ការយោងទៅលើសក្ខីកម្មរបស់សាក្សី ខឹម ហឿន នៅក្នុងសំណុំរឿង ០០២ មិនត្រូវបានធ្វើការកោសលុបនោះទេ[23] ដោយឡែកសេចក្តីយោងនានាចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ នៅក្នុងសំណុំរឿង ០០៤ គឺត្រូវបានកោសលុប[24] ។

- ផ្ទុយទៅនឹងការអនុវត្តរបស់អង្គបុរេជំនុំជម្រះនៅពេលចេញសេចក្តីសម្រេច និងការពិចារណានានា ជាឯកសារកោសលុបសាធារណៈ[25] ក្រុមការពារក្តី ស្នើសុំរក្សាទុកដោយឥតកោសលុបលើឈ្មោះអ្នកស្រី អ៊ឹម ចែម ។ ការធ្វើរបៀបនេះ វាស្របទៅនឹងសេចក្តីសង្ខេបសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងនៅក្នុងដីកាដំណោះស្រាយជាសំណៅកោសលុបដែលក្នុងនោះអ្នកស្រី អ៊ឹម ចែម ត្រូវបានកំណត់ថាជាជនត្រូវចោទក្នុងសំណុំរឿង ០០៤/១ និងជាបុគ្គលម្នាក់ដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យធ្វើការចោទប្រកាន់ ។

- ក្រុមការពារក្តីសូមស្នើឱ្យរក្សាទុកឥតកោសលុបលើឈ្មោះកម្មាភិបាលមន្ត្រីខ្មែរក្រហម ដែលបានស្លាប់ លើកលែងតែឈ្មោះរបស់អ្នកទាំងនោះ ត្រូវបានកោសលុបរួចហើយពីក្នុងសំណៅកោសលុបនៃដីកាដំណោះស្រាយ ។ ឧទាហរណ៍ ឈ្មោះ *តា* ម៉ុក, *តា* រិន, *តា* ហ៊ីង, *តា* សោម, *តា* ចាយ, និង *តា* វ៉ាល់ សុទ្ធតែត្រូវបានរក្សាទុកនៅក្នុងសំណៅកោសលុបនៃដីកា

---

[21] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៧ ។

[22] *សូមមើល*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ៧០ ។

[23] *សូមមើល*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ៧៨ ។

[24] *សូមមើល*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ៩០ ។

[25] *សូមមើលជាឧទាហរណ៍*, សេចក្តីពិចារណាលើ[សំណៅកោសលុប]សំណើរបស់ អ៊ឹម ចែម សុំធ្វើមោឃភាពប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធ្វើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦, ឯកសារ **D298/2/1/3** ។

ដំណោះស្រាយ[26] ដោយឡែកតែឈ្មោះ តា ពាល់ គឺមិនត្រូវបានរក្សាទុកឡើយ[27] ។ លើសពីនេះ ក្រុមការពារក្តីបានអនុវត្តវិធីសាស្ត្រដ៏ប្រយ័ត្នប្រយែង ពាក់ព័ន្ធនឹងកម្មាភិបាលខ្មែរក្រហមទាំងឡាយណាដែលបានស្លាប់ និងដោយឈ្មោះអ្នកទាំងនោះមិនមានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ទេនោះ យើងខ្ញុំស្នើសុំធ្វើការកោសលុបលើឈ្មោះពួកគេចេញ ដូចមាននៅក្នុងឧបសម្ព័ន្ធ A ។ គំរូយ៉ាងដូចជាឈ្មោះ *តា* ឡៃ[28], ផុន[29], ធួក[30] និង ហួរ[31] ជាដើម ។

- ពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្រុមការពារក្តីសូមស្នើឱ្យរក្សាទុកទាំងអស់នូវរាល់ការយោងសេចក្តីជាសំអាងនានា ។ ទង្វើនេះ វាស្របទៅនឹងសេចក្តីសង្ខេបសាធារណៈ ដែលក្នុងនោះសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ពីគោលជំហររបស់គាត់ទាក់ទងនឹងសំណុំរឿង០០៤/១ ជាសាធារណៈ ។ លើសពីនេះ ការធ្វើដូច្នេះ នឹងអនុញ្ញាតឱ្យសាធារណជនអាចពិនិត្យពិច័យមើលបានហ្មត់ចត់ ទៅតាមបរិបទសមស្រប នូវអំណះអំណាងជាក់លាក់ដែលក្រុមការពារក្តីបានជំទាស់តវ៉ានៅក្នុងចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

- ចុងបញ្ចប់ ក្រុមការពារក្តីសូមស្នើឱ្យរក្សាទុកឥតកោសលុប នូវឯកសារយោងទាំងអម្បាលម៉ានដែលមាននៅក្នុងសំណុំរឿង ០០៤/១ ដូចជា សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[32] ។ ជាការពិតណាស់ ក្រុមការពារក្តីនឹងស្វះស្វែងស្នើសុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញសម្រាប់ឯកសារទាំងនេះនាពេលឆាប់ៗ ដោយ

---

[26] *សូមមើលជាឧទាហរណ៍*, [កោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ("ដីកាដំណោះស្រាយជាសំណៅកោសលុប, ឯកសារ **D308/3**"), ត្រង់កថាខណ្ឌ ១៤១, ១៤៧, ១៥៥, ១៦២ ។

[27] *សូមមើលជាឧទាហរណ៍*, ដីកាដំណោះស្រាយជាសំណៅកោសលុប, ឯកសារ **D308/3**, ត្រង់កថាខណ្ឌ ២២៩ ។

[28] *សូមមើលជាឧទាហរណ៍*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ១០១ ។

[29] *សូមមើលជាឧទាហរណ៍*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ១០២ ។

[30] *សូមមើលជាឧទាហរណ៍*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ១៣៦ ។

[31] *សូមមើលជាឧទាហរណ៍*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ១៣៦ ។

[32] *សូមមើលជាឧទាហរណ៍*, ឧបសម្ព័ន្ធ A ត្រង់កថាខណ្ឌ ២, ១០ និង ១៦ ។

ផ្អែកលើហេតុផលដូចគ្នា ដូចបានលើកឡើងក្នុងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញពោលគឺ ដើម្បីអនុញ្ញាតឱ្យការបរិយាយរបស់ក្រុមការពារក្តី ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងដើម្បីលើកកម្ពស់ផលប្រយោជន៍យុត្តិធម៌ និងតម្លាភាពនៃដំណើរការនីតិវិធី ។

**ខ. ការធ្វើចំណាត់ប្រភេទឯកសារនៃការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ត្រូវបានធានាដោយផលប្រយោជន៍យុត្តិធម៌**

១៨. ខណៈដែលភាពសម្ងាត់នៃការស៊ើបសួរតាមផ្លូវតុលាការ គឺជាគោលការណ៍ទូទៅនៅដំណាក់កាលមុនមានការជំនុំជម្រះ[33] វាត្រូវតែបានធ្វើតុល្យការជាចុងក្រោយទល់នឹងផលប្រយោជន៍យុត្តិធម៌[34] និងតម្រូវការសម្រាប់សាធារណជនទទួលបានព័ត៌មាន និងការអប់រំអំពីដំណើរការនីតិវិធី[35] ។ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ នឹងធានាបានទាំងតម្លាភាពនៃដំណើរការនីតិវិធី ទាំងការផ្សព្វផ្សាយនូវព័ត៌មានសំខាន់ៗដែលមានភាពត្រឹមត្រូវ និងមានតុល្យភាព ដើម្បីផ្តល់ការយល់ដឹងជាសាធារណៈឱ្យបានពេញលេញអំពីដំណើរការនីតិវិធី ។ ទាក់ទងទៅនឹងការទាមទារឱ្យមានតម្លាភាព អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដូច្នេះថា៖

> ការធ្វើចំណាត់ថ្នាក់លើឯកសារ ត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងតម្រូវការនៃការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាពដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរដំណែល[36] ។

១៩. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ នឹងរួមចំណែក

---

33 *សូមមើល*, វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង ។

34 *សូមមើល*, សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី៨), អវតក/០១/២០០៧/វិ.លើកទី ៨, ធ្វើនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ត្រង់មាត្រា ៣.១៤ ។

35 *សូមមើល*, សេចក្តីណែនាំឱ្យអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិសោធនកម្មលើកទី២), អវតក/០០៤/២០០៨/វិ.លើកទី ២, ធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៤ ត្រង់មាត្រា ១.២ ។

36 *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2**, ត្រង់កថាខណ្ឌ ៥ ។

ដល់ការយល់ដឹងជាសាធារណៈ និងមានតម្លាភាព ដោយការបង្ហាញពីទឡ្ហីករណ៍នានារបស់ក្រុមការពារក្តីឱ្យសាធារណជនបានដឹងឮ ។ ក្នុងន័យនេះ ការពិពណ៌នាជាសាធារណៈនាពេលបច្ចុប្បន្ន ដោយផ្អែកលើអ្វីដែលអាចរកមើលបានពីបណ្តាញប្រព័ន្ធអ៊ីនធឺណិត គឺឃើញថាមានទំនោរផ្តល់នូវកំណត់ត្រាសាធារណៈមិនត្រឹមត្រូវ និងធ្វើឱ្យសាធារណជនយល់ខុស[37] ។

២០. មានសេចក្តីយោងជាសាធារណៈតិចតួចណាស់ លើកឡើងពីទឡ្ហីករណ៍របស់ក្រុមការពារក្តីទាក់ទងនឹងបញ្ហាអង្គច្បាប់ និងអង្គហេតុខុសៗគ្នា ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ ។ សាធារណជននៅតែមិនបានដឹងអំពីអំណះអំណាងរបស់ក្រុមការពារក្តី ដែលពន្យល់អំពីផ្នែកនៃសេចក្តីសម្រេចចុងក្រោយ *ចំណោមនោះ* រួមមានដូចជាទឡ្ហីករណ៍ដែលក្រុមការពារក្តីបង្ហាញថា៖ i) សហព្រះរាជអាជ្ញាអន្តរជាតិបានអនុវត្តវិធីសាស្ត្រទូលំទូលាយហួសពីការចោទប្រកាន់ ជាហេតុនាំឱ្យមានការប្ញូកបញ្ចូលទាំងអង្គហេតុមិនពាក់ព័ន្ធ លើសពីវិសាលភាពដែលអាចអនុញ្ញាតឱ្យធ្វើទៅបានសម្រាប់ដីកាសន្និដ្ឋានស្ថាពរ[38] ii) ការសន្មតលើបញ្ហាតួនាទី និងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម

---

[37] *សូមមើល*, សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០៤/១; សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤ ចេញផ្សាយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥, អាចចូលមើលបាន៖ https://www.eccc.gov.kh/en/articles/international-co-investigating-judge-charges-im-chaem-absentia-case-004 ។ *សូមមើលផងដែរ*, អត្ថបទសារព័ត៌មាន៖ ដោយ G. Wright, [ភាសាអង់គ្លេស] *"Tribunal Judge Defends Laying Absential Charges"*, កាសែត ខឹមបូឌាដេលី, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥, អាចចូលមើលបាន៖ https://www.cambodiadaily.com/archives/tribunal%E2%80%88judge-defends-laying-absentia-charges-86991/; អត្ថបទសារព័ត៌មានដោយ E. Handley, [ភាសាអង់គ្លេស] *"Im Chaem filing short on reasoning"*, កាសែតភ្នំពេញប៉ុស្តិ៍, ចុះផ្សាយនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧, អាចចូលមើលបាន៖ http://www.phnompenhpost.com/national/im-chaem-filing-short-reasoning ។ អត្ថបទសារព័ត៌មាន៖ ដោយ AFP, [ភាសាអង់គ្លេស] *"Off the hook for mass murder, Khmer Rouge cadre turns to God"*, កាសែត Daily Nation, ចុះផ្សាយនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៨, អាចចូលមើលបាន៖ https://www.nation.co.ke/news/world/Khmer-Rouge-leader-turns-to-God/1068-4327728-5tiyt7/index.html ["ឯកសារចោទប្រកាន់ពីសហព្រះរាជអាជ្ញា[អន្តរជាតិ] បានឱ្យដឹងថា មានប្រជាជនប្រមាណជា ៤០.០០០ នាក់ ត្រូវបានស្លាប់ដោយសារការសម្លាប់ ភាពអត់ឃ្លាន និងធ្វើការងារហួសកម្លាំង នៅមន្ទីរឃុំឃាំងដ៏ធំបំផុតក្នុងភ្នំទ្រយោង នាចន្លោះឆ្នាំ ១៩៧៧ និង ១៩៧៨"] ។

[38] *សូមមើល*, ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** ត្រង់កថាខណ្ឌ ២០-២៩ ។ ក្រុមការពារក្តីកត់សម្គាល់ឃើញថា ខណៈពេលដែលដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតបានសម្រេចគាំទ្រលើអំណះអំណាងលើក

ដោយសហព្រះរាជអាជ្ញាអន្តរជាតិ មិនអាចបំពេញបង្គ្រប់យកជាភស្តុតាងបានឡើយ ដោយសារតែផ្នែកខ្លះនៃរបៀបដែលសហព្រះរាជអាជ្ញាអន្តរជាតិអនុវត្តចំពោះភស្តុតាង គឺត្រូវបានរកឃើញថាមានកំហុសជាច្រើន[39] iii) សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិលើលក្ខណៈវិនិច្ឆ័យចំពោះពាក្យពេចន៍នៃ "ការទទួលខុសត្រូវបំផុត" ឬក្បួនទាំងការខកខានមិនបានយកចិត្តទុកដាក់ក្នុងការពិនិត្យពិច័យលើភស្តុតាងពាក់ព័ន្ធ គឺជាចំណុចមួយដែលគ្មានអ្នកវិនិច្ឆ័យអង្គហេតុដ៏មានហេតុផលណាម្នាក់ អាចនឹងអនុវត្តទៅកើតឡើយ[40] និង iv) បង្ហាញថា អ្នកស្រី អ៊ឹម ចែម មិនបានដើរតួនាទីទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភ្នំត្រយោង ឬក៏នៅការដ្ឋានស្ពានស្រែងនោះទេ[41] ។

២១. តម្លាភាពនៃកិច្ចដំណើរការនីតិវិធី គឺជាបញ្ហាមួយដែលបាន និងកំពុងតែបន្តខ្វល់ខ្វាយយកចិត្តទុកដាក់ ហើយជាផលប្រយោជន៍សាធារណៈយ៉ាងសំខាន់ក្រៃលែង[42] ។ ការធ្វើចំណាត់ឯកសារឡើង

---

ឡើងដោយក្រុមការពារក្តីត្រង់បញ្ហានេះក៏ដោយ ក៏ដីកាដំណោះស្រាយនៅផ្នែកនេះ ត្រូវបានកោសលុបចេញនៅក្នុងសេចក្តីសម្រេចដែលអាចរកមើលបានជាសាធារណៈ ។ *សូមមើល*, [សំណៅកោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៤-៤៥ ។

39 *សូមមើល*, ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** ត្រង់កថាខណ្ឌ ២៩-៣៦ ។

40 *សូមមើល*, ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** កថាខណ្ឌ ៣០-៣៦, ៥៤-៦០។ *សូមមើលផងដែរ*, ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** ត្រង់កថាខណ្ឌ ២០-២៩ ។

41 *សូមមើល*, ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/6** ត្រង់កថាខណ្ឌ ១៤៤-២២៦ ។

42 *សូមមើលជាឧទាហរណ៍, រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, សំណើរបស់ អៀង សារី សុំឲ្យធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាប្រភេទឯកសារសាធារណៈ: *ញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ* ធ្វើនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារ **E71/1/2**, ត្រង់កថាខណ្ឌ ១២; អត្ថបទសារព័ត៌មានដោយ៖ Fédération Internationale des Droits de l'Homme, [ជាភាសាអង់គ្លេស] "ECCC: Call for transparency and independence of proceedings in Cases 003 and 004, and for an effective implementation of victims' rights to participate" ចុះផ្សាយនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, អាចចូលមើលបាននៅ៖ https://www.fidh.org/en/region/asia/cambodia/eccc/ECCC-Call-for-transparency-and; អត្ថបទដោយ K. Nelson, [ជាភាសាអង់គ្លេស]៖ "The Presumption of Confidentiality at the ECCC: The Need for Standards to Protect Private Investigations, Provide Consistent Public Access, and Increase Transparency" ពីព្រឹត្តិប័ត្រ *ស្វែងរកការពិត* (មជ្ឈមណ្ឌលឯកសារកម្ពុជា, ខែ កញ្ញា ឆ្នាំ ២០១០), អាចចូលមើលបាននៅ៖

វិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាពរជាប្រភេទឯកសារសាធារណៈ នឹងជូនដំណឹងដល់សាធារណជនទូទៅបានដឹងពីអំណះអំណាងរបស់ក្រុមការពារក្ដី ដើម្បីឱ្យពួកគេទទួលបាននូវការយល់ដឹងកាន់តែត្រឹមត្រូវ និងមានតុល្យភាពលើបញ្ហានីតិវិធីតុលាការប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ដើម្បីពួកគេអាចពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់លើសារណានានាពីសំណាក់ភាគីទាំងអស់ និងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងរង្វង់បរិបទរបស់វា ព្រមទាំងដើម្បីទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត។ ការធ្វើចំណាត់ឯកសារឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាពរជាប្រភេទឯកសារសារធារណៈ គឺជាវិធានការដ៏សមហេតុសមផលមួយ ដែលនឹងជួយដល់សាធារណជនក្នុងការស្វែងយល់អំពីដំណើរការនីតិវិធី និងជួយកាត់បន្ថយនូវការយល់ខុសទាំងឡាយណាដែលទាក់ទងនឹងសេចក្ដីសម្រេចលើសំណុំរឿង ភាពសុចរិតនៃដំណើរការនីតិវិធី ក៏ដូចជាកេរដំណែលនៃ អ.វ.ត.ក ។

២២. ដោយពិចារណាចំពោះហេតុផលខាងលើ និងដោយអនុលោមទៅតាមមាត្រា ៩.៣ សេចក្ដីណែនាំការអនុវត្តស្ដីពីចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ក្រុមការពារក្ដីសូមដាក់សំណៅកោសលុបនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាពរក្នុងឧបសម្ព័ន្ធ A ជូនអង្គបុរេជំនុំជម្រះសម្រាប់ធ្វើការត្រួតពិនិត្យមើល និងអនុម័ត ។

## V. សំណើ

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្ដីសូមស្នើអង្គបុរេជំនុំជម្រះដោយគោរពមេត្តា i) បង្គាប់ដល់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ឱ្យដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាពរជាទម្រង់ឯកសារកោសលុបសាធារណៈ ដោយភ្ជាប់ជាមួយនឹងសំណូមពរសុំធ្វើការកោសលុបត្រង់ផ្នែកខ្លះ ដូចមាននៅក្នុងឧបសម្ព័ន្ធ A និង ii) ធ្វើចំណាត់ឯកសារនៃសំណើនេះឡើងវិញ ជាប្រភេទឯកសារសាធារណៈ ៕

សូមមេត្តាទទួលយកសារណានេះដោយគោរព ។

---

http://www.genocidewatch.org/images/Cambodia_10_09_xx_The_Presumption_of_Confidentiality_at_the_ECCC_The_need_for_standards_to_protect_private_investigations_Provide_consistent_public_access_And_increase_transparency.doc.

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨

សហមេធាវីការពារក្តីអ្នកស្រី អ៊ឹម ចែម

| [ហត្ថលេខា] | [ហត្ថលេខា] |
|---|---|
| ____________ | ____________ |
| ប៊ិត ស៊ាងលឹម | Wayne JORDASH, QC |